# ការសិក្សាពីកុមារវ័យ

***សុជាខ្ញុំ*** *អាយុ ៧ ឆ្នាំបានចូលរៀនថ្នាក់ដំបូងនៅសាលាបឋម-សិក្សាវត្តពោធិមន្ត្រី ដែលនៅជិតភូមិ ។ មួយឆ្នាំបន្ទាប់* ***សុជាខ្ញុំ****ត្រូវបានអ្នកគ្រូជ្រើសឲ្យឡើងទៅថ្នាក់ទី ១ ហើយលោកគ្រូនាយក និងគ្រូប្រចាំថ្នាក់ស្រឡាញ់រាប់អានណាស់ ព្រោះខ្ញុំរៀនបានពិន្ទុល្អ ចាត់ទុកថាជាសិស្សឆ្លាតគ្រាន់បើ ប៉ុន្តែបានពាក់កណ្តាលឆ្នាំ ស្ថានភាពគ្រួសារធ្វើឲ្យការសិក្សារបស់ខ្ញុំមិនរីកចម្រើនសោះ ។ ខ្ញុំចាំបានថា កាលនោះគ្រួសារ****សុជាខ្ញុំ****នៅសល់តែគោមួយក្បាលគត់ លោកឪពុកក៏សម្រេចចិត្តលក់គោនោះ ទៅទិញកូនទាចំនួនប្រាំរយក្បាលមកចិញ្ចឹម តាំងពីពេលនោះមក* ***សុជាខ្ញុំ****ក៏ក្លាយជាមនុស្សសកម្មម្នាក់ក្នុងគ្រួសារ គឺក្លាយជាអ្នកឃ្វាលទា ដោយក្រោកឡើងតាំងពីម៉ោង ៤ ព្រឹកទៅអូសកំពឹសនិងកូនត្រីឲ្យទាស៊ី សូម្បីតែខែរងាញ័រថ្គាមក៏ត្រូវតែធ្វើដែរ លុះម៉ោងប្រហែល ៧ ព្រឹក ក៏បណ្តើរកូនទាកាត់តាមវាលស្រែឲ្យចាប់ចំណី ។ ក្រោយរដូវប្រូតកាត់* ***សុជាខ្ញុំ****ពុំសូវបានដេកនៅផ្ទះទេ លោកឪពុកបានយកទ្រុងទា ទៅធ្វើនៅកន្លែងណាដែលគេទើបតែប្រូតរួចដើម្បីខ្ញុំបណ្តើរទាឲ្យរើសគ្រាប់ស្រូវដែលធ្លាក់ក្នុងស្រែស៊ី ហើយពេលយប់ត្រូវដេកក្នុងរោងទានោះឯង ឯរោងទាត្រូវផ្លាស់ពីកន្លែង*

មួយទៅកន្លែងមួយជាញឹកញាប់.......... ម្ល៉ោះហើយការសិក្សារបស់ខ្ញុំកាន់តែធ្លាក់ទៅ ៗ ព្រោះក្នុងមួយឆ្នាំ ៗ ខ្ញុំចូលរៀនបានតែពីរ ឬ បីខែប៉ុណ្ណោះ គឺពេលចូលកងបានប្រហែលជាងមួយខែ និងមុនឡើងថ្នាក់ប្រហែលជាងមួយខែ ប៉ុន្តែដោយឃើញថា**សុជាខ្ញុំ** ថ្វីដ្បិតតែមិនឈ្នះគេក្នុងចំណោមសិស្សពូកែ តែក៏អាចរៀនប្រហាក់ប្រហែលនឹងអ្នកមធ្យម ម្ល៉ោះហើយ លោកគ្រូអ្នកគ្រូនៅតែឲ្យខ្ញុំឡើងថ្នាក់រហូតថែមទាំងឲ្យខ្ញុំឡើងផ្លោះពីថ្នាក់ទី៣ ទៅថ្នាក់ទី៥ ដោយមិនបានរៀនថ្នាក់ទី ៤ ទេ ។ ការដែលខ្ញុំឈប់ច្រើននៅតែរៀនទាន់គេ ព្រោះពេលឈប់ខ្ញុំខំរៀនដោយខ្លួនឯង ត្រង់ណាដែលមិនយល់ខ្ញុំតែងទៅសាកសួរអ្នកជិតខាងដែលគេរៀនបានច្រើន ។ ពេលដែលខ្ញុំមិនបានទៅរៀនអស់កាលយូរថ្ងៃ ខ្ញុំតែងតែបានទទួលសំបុត្រពីគ្រូប្រចាំថ្នាក់ ដែលសរសេរមកលួងលោមឲ្យខ្ញុំត្រឡប់ទៅរៀនវិញ ជួនកាល**សុជាខ្ញុំ**អានសំបុត្រទាំងស្រក់ទឹកភ្នែក ដោយអរគុណលោកគ្រូអ្នកគ្រូណាស់ដែលមិនបញ្ឈប់ការសិក្សារបស់ខ្ញុំ ហើយតែងតែលើកទឹកចិត្តជានិច្ចតែមិនដឹងធ្វើយតបទៅវិញដោយរបៀបណា នឹកកម្សត់តែម្នាក់ឯងចង់ទៅរៀនវិញ តែលៃមិនកើត ព្រោះគ្មានអ្នកជំនួស ម្យ៉ាងទៀតលោកឪពុកជាប់រវល់ធ្វើនេសាទកម្មនិងកសិកម្ម បងប្រុសត្រូវទៅរៀននៅ

អនុវិទ្យាល័យ ឯប្អូន ៗ សុទ្ធតែស្រី ។ ដោយសារការរៀនរំលងថ្នាក់ផង ដោយការឈប់ច្រើនពេកផង ទោះបីខ្ញុំរៀនខ្លួនឯងយ៉ាងណា ក៏ខ្ញុំដឹងខ្លួនឯងថា ខ្ញុំរៀនមិនទាន់គេទេ កាលនោះខ្ញុំបានចំណាត់ថ្នាក់លេខ ១៧ ក្នុងចំណោមសិស្សប្រហែល ១៨ នាក់ ។ លុះចុងឆ្នាំ ខ្ញុំក៏បានចុះឈ្មោះប្រលងចូលអនុវិទ្យាល័យ លទ្ធផលគឺ "**ធ្លាក់**" ។ ក្នុងឆ្នាំនោះដែរ វដ្តបានបញ្ជូនលោកឪពុកទៅ ក៥ ឯអ្នកម្តាយក៏លក់ទាចោល រួចទិញគោវិញ ។ ចាប់ពីពេលនោះមក **សុជាខ្ញុំ**មានពេល វេលាគ្រប់គ្រាន់ដើម្បីសិក្សា ។ ខ្ញុំធ្លាប់សន្យានឹងប្អូនស្រីខ្ញុំថា "បើរៀនមិនបានលេខ ១ នឹងកាត់ម្រាមដៃឲ្យឆ្កែស៊ី" ដូចបំណងមែន ឆមាសទី ១ បានលេខ ២ ឆមាសទី ២ បានលេខ ១ ពេលទៅប្រលងចូលអនុវិទ្យាល័យក៏ជាប់ទៀត ។ អ្វី ៗ មិនដូចបំណងទេ បានម្យ៉ាងខ្វះម្យ៉ាង **សុជាខ្ញុំ**ថ្វីដ្បិតតែអាយុ ១៤ ឆ្នាំហើយ តែមាឌល្អិតដ្បិតឈឺច្រើន ធាក់កង់ទៅរៀនមិនរួច ព្រោះផ្លូវឆ្ងាយកាត់វាលស្រែ រីឯខែទឹកជន់ក៏លំបាកធ្ងន់ ម្ល៉ោះហើយលោកឪពុកអ្នកម្តាយបានឲ្យខ្ញុំទៅស្នាក់នៅ ជាមួយអ៊ុំស្រីជីដូនមួយឈ្មោះ **អៀង សុផល** ហៅ **អ៊ាប** នៅភូមិ អង្កាញ់ ដែលមានទីតាំងមិនឆ្ងាយប៉ុន្មានពីសាលាអនុវិទ្យាល័យដូងខ្ពស់ ។ ខ្ញុំស្នាក់នៅទីនោះប្រហែល

ពីបីទៅបួនខែ ដល់រដូវសម្រកក៏លាអ៊ុំស្រីទៅផ្ទះវិញ ទ្រាំជិះកង់ទៅរៀនទាំងត្រជាបត្រជួស ។

# វិស័យសិល្បៈ

អំណោយពីធម្មជាតិ **សុជាខ្ញុំ**មានសម្លេងពីរោះគ្រាន់បើដែរ អាចច្រៀងបំពេរចាស់ ៗ ក្នុងភូមិឲ្យត្រជាក់ចិត្តបាន ប៉ុន្តែការនេះទាល់តែមានរង្វាន់ទើបច្រៀង មិនចេះតែច្រៀងឲ្យស្តាប់ដោយទទេ ៗ ឬច្រៀងឡូឡាដើម្បីសប្បាយឡើយ ។ **សុជាខ្ញុំ**ចេះច្រៀងតាំងពីមិនទាន់ចេះស្លៀកខោម៉្លេះ ក្រោយមកខ្ញុំរៀនច្រៀងតាមលោក **កែវ សារ៉ាត់** អ្នកស្រុកស្តាប់ហើយពោលសរសើរថា ដូច **កែវ សារ៉ាត់** បេះបិទ តាំងពីពេលនោះមក អ្នកស្រុកហៅ**សុជាខ្ញុំ**ថា **សារ៉ាត់ក្មេង** ហើយក្លាយជាអ្នកចម្រៀងប្រចាំសាលាតាំងពីបឋមសិក្សាមកម៉្លេះ ។ ក្រៅពីច្រៀង ខ្ញុំអាចហួចបានគ្រប់បទ ហើយការហួចទៀតសោត ខ្ញុំហួចមិនឲ្យដាច់សម្លេងទេ គឺហួចទាល់តែចប់បទមួយ ៗ ទើបឈប់ ដោយប្រើទាំងខ្យល់ចេញនិងខ្យល់ចូល អ្នកស្រុកស្តាប់ទៅ ឮហាក់ដូចជាខ្ញុំមិនដកដង្ហើមអ៊ីចឹង លើសពីនេះ ខ្ញុំអាចហួចធ្វើជាសម្លេងខ្ទុយបាន ព្រោះហេតុនោះ ចាស់ ៗ ហៅខ្ញុំថា **កុមារខ្ទុយទិព្វ** ។